ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# កិច្ចព្រមព្រៀង

រវាង

# គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ)

និង

# អង្គការឃែរអន្តរជាតិប្រចាំកម្ពុជា

ស្តីពី

# កិច្ចសហប្រតិបត្តិការអនុវត្តគម្រោងចំណាកស្រុកឆ្លងដែនដោយសុវត្ថិភាព

# បុព្វកថា

**ដោយហេតុថា ៖** គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) បានសម្តែងនូវបំណងប្រាថ្នា ក្នុងការរួមសហការជាមួយអង្គការឃែរអន្តរជាតិប្រចាំកម្ពុជា ដែលមានបេសកកម្ម ក្នុងការលើកកម្ពស់កិច្ចការពារពលករទេសន្តរប្រវេសន៍ចំណាកស្រុកជាពិសេសស្ត្រី និងកុមារ ការទប់ស្កាត់អំពើហិង្សាលើស្ត្រី និងការបង្ការហានិភ័យក្នុងអំឡុងពេលធ្វើចំណាកស្រុកឆ្លងដែន និងអំពើជួញដូរមនុស្ស ។

**ដោយយល់ថា ៖** ការអនុវត្តគម្រោងចំណាកស្រុកដោយសុវត្ថិភាព ដែលកាត់បន្ថយភាពរងគ្រោះដោយអំពើជួញដូរមនុស្ស និងការកេងប្រវ័ញ្ចគ្រប់រូបភាពក្នុងអំឡុងពេលធ្វើទេសន្តរប្រវេសន៍ គឺដើម្បីចូលរួមធ្វើឱ្យសម្រេចបាននូវផែនការយុទ្ធសាស្ត្រជាតិស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងគោលនយោបាយភូមិឃុំមានសុវត្ថិភាពរបស់រាជរដ្ឋាភិបាល ។

**ដោយយល់ថា ៖** គម្រោងរបស់អង្គការឃែរប្រចាំកម្ពុជា ផ្តោតសំខាន់ទៅលើក្រុមដែលងាយរងគ្រោះជាស្ត្រី បុរស កុមារា កុមារី ដែលប្រឈមនឹងការចំណាកស្រុកដោយគ្មានសុវត្ថិភាព និងអំពើជួញដូរមនុស្ស នៅក្នុងខេត្តកំពង់ស្ពឺ និងខេត្តព្រះសីហនុ នៃព្រះរាជាណាចក្រកម្ពុជា និងក្នុងខេត្តត្រាត នៃព្រះរាជាណាចក្រថៃ ។

# ប្រការ១
# គោលបំណង

កិច្ចព្រមព្រៀងនេះ មានគោលបំណងបង្កើនកិច្ចសហប្រតិបត្តិការរវាងគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) និងអង្គការឃែរអន្តរជាតិប្រចាំកម្ពុជា ក្រោមការគាំទ្រពីអង្គការ UN WOMEN[1] ដើម្បី៖

- លើកកម្ពស់សុវត្ថិភាព និងសមភាពយេនឌ័ររបស់ក្រុមជនងាយរងគ្រោះជាស្ត្រី បុរស កុមារា កុមារី ដែលប្រឈមនឹងភាពរងគ្រោះក្នុងអំឡុងពេលធ្វើចំណាកស្រុកឆ្លងដែនប្រកបដោយសមធម៌ និងគ្មានការរើសអើង ព្រមទាំងផ្តល់ភាពអង់អាចដល់ស្ត្រី ។
- ពង្រឹងការអនុវត្តគម្រោងចំណាកស្រុកឆ្លងដែនដោយសុវត្ថិភាព ស្របតាមផែនការយុទ្ធសាស្ត្រជាតិរបស់ គ.ជ.ប.ជ ។

[1] តាមរយៈកម្មវិធីសុវត្ថិភាព និងយុត្តិធម៌ដែលជាផ្នែកមួយ នៃគំនិតផ្តួចផ្តើម Spotlight ដើម្បីលុបបំបាត់អំពើហិង្សាលើស្ត្រី និងកុមារីដែលអនុវត្តក្នុងភាពជាដៃគូរវាងសហភាពអឺរ៉ុប និងអង្គការសហប្រជាជាតិ

## ប្រការ ២
## ការទទួលខុសត្រូវរបស់គណៈកម្មាធិការជាតិ
## ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ)

**ដើម្បីឱ្យការអនុវត្តកិច្ចព្រមព្រៀងនេះទទួលបានជោគជ័យ និងមានប្រសិទ្ធភាពខ្ពស់ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានព្រមព្រៀងដូចខាងក្រោម ៖**

១. គាំទ្រ និងសហការអនុវត្តគម្រោងចំណាកស្រុកឆ្លងដែនរបស់អង្គការយែរអន្តរជាតិប្រចាំកម្ពុជាក្នុងខេត្តគោលដៅ (កំពង់ស្ពឺ និងព្រះសីហនុ) នៃព្រះរាជាណាចក្រកម្ពុជា និងខេត្តត្រាត នៃព្រះរាជាណាចក្រថៃ ។

២. ជួយសម្របសម្រួលដោះស្រាយបញ្ហាប្រឈមដែលកើតមានឡើងក្នុងខេត្តគោលដៅ អំឡុងពេលអនុវត្តគោលបំណងគម្រោងដូចមានចែងខាងលើ ។

៣. រាល់ទំនាក់ទំនងការងារសម្រាប់ដំណើរការសកម្មភាពគម្រោង លេខាធិការដ្ឋាន នៃគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សខេត្តកំពង់ស្ពឺ និងខេត្តព្រះសីហនុ មានតួនាទីសម្របសម្រួល សហការ និងតាមដានប្រសិទ្ធភាព នៃកិច្ចសហការរវាងបុគ្គលិកគម្រោងអង្គការយែរអន្តរជាតិប្រចាំកម្ពុជា និងមន្ត្រីពាក់ព័ន្ធថ្នាក់ក្រោមជាតិ ព្រមទាំងធ្វើរបាយការណ៍មកអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ក្នុងករណីចាំបាច់។

៤. អនុញ្ញាតឱ្យអង្គការយែរអន្តរជាតិប្រចាំកម្ពុជាដែលកំពុងធ្វើសកម្មភាពគម្រោង ចូលរួមប្រជុំលេខាធិការដ្ឋានខេត្តគោលដៅ ដើម្បីចែករំលែកបច្ចុប្បន្នភាពទិន្នន័យដែលជាលទ្ធផលគម្រោង ក៏ដូចជាកង្វល់ បញ្ហាប្រឈម និងសំណូមពរនានាដែលត្រូវរួមគ្នាដោះស្រាយ។

៥. បន្តនិរន្តរភាព នៃគម្រោងរបស់អង្គការយែរអន្តរជាតិប្រចាំកម្ពុជាដែលមានស្រាប់ក្នុងសហគមន៍គោលដៅ និងដែលកំពុងផ្តល់ផលប្រយោជន៍លើជីវភាពរបស់ក្រុមគោលដៅ។

៦. អនុញ្ញាតឱ្យអង្គការយែរអន្តរជាតិប្រចាំកម្ពុជាចូលរួមក្នុងកិច្ចប្រជុំដែលរៀបចំឡើងដោយគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) ដើម្បីចែករំលែកព័ត៌មាន បទពិសោធន៍ និងសមិទ្ធផលការងារដែលទទួលបានទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ។

## ប្រការ ៣
## ការទទួលខុសត្រូវរបស់អង្គការយែរអន្តរជាតិប្រចាំកម្ពុជា

**ដើម្បីឱ្យការអនុវត្តកិច្ចព្រមព្រៀងនេះទទួលបានជោគជ័យ និងមានប្រសិទ្ធភាពខ្ពស់ អង្គការយែរអន្តរជាតិប្រចាំកម្ពុជា បានព្រមព្រៀងដូចខាងក្រោម ៖**

១. សហការយ៉ាងជិតស្និទ្ធជាមួយគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) នៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដើម្បីធ្វើឱ្យសម្រេចគោលបំណងគម្រោង ។

២. អង្គការយែរអន្តរជាតិប្រចាំកម្ពុជានឹងបញ្ជូនរាល់របាយការណ៍សកម្មភាព អត្ថបទ ឬខ្លឹមសារនៃសារដែលត្រូវបោះពុម្ព ផ្សព្វផ្សាយ និងបណ្តុះបណ្តាលពាក់ព័ន្ធនឹង ការធ្វើចំណាកស្រុកឆ្លងដែនដោយសុវត្ថិភាព ការបង្ការទប់ស្កាត់អំពើហិង្សាលើស្ត្រី និងសកម្មភាពប្រយុទ្ធប្រឆាំងនឹងអំពើជួញដូរមនុស្ស ទៅអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ និងចម្លងជូនលេខា-ធិការដ្ឋាន គ.ខ.ប.ជ នៃខេត្តគោលដៅដើម្បីពិនិត្យផ្តល់យោបល់រកការឯកភាពមុននឹងធ្វើការផ្សព្វផ្សាយ។

៣. ផ្តល់កិច្ចគាំទ្របច្ចេកទេស ថវិកា និងសម្ភារចាំបាច់ ទៅតាមលទ្ធភាពនៃគម្រោង (ដែលស្របតាមការសម្រេចចិត្តពីម្ចាស់មូលនិធិ) ដើម្បីពង្រឹងសកម្មភាពជាអន្តរាគមន៍ចាំបាច់ឆ្លើយតបនឹងសំណើរបស់ គ.ជ.ប.ជ សម្រាប់ការដោះស្រាយបញ្ហាចំណាកស្រុក និងការជួញដូរមនុស្ស ។

៤. ផ្តល់នូវការទូទាត់ចំណាយប្រាក់បេសកកម្មនៅក្នុង និងក្រៅប្រទេសសម្រាប់មន្ត្រីថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដែលបំពេញបេសកកម្មក្នុងក្របខណ្ឌគម្រោង (ស្របតាមអនុក្រឹត្យលេខ២១៦របស់រាជរដ្ឋាភិបាលកម្ពុជា) ។

៥. ចូលរួមប្រជុំលេខាធិការដ្ឋានខេត្តគោលដៅ ដើម្បីចែករំលែកបច្ចុប្បន្នភាពទិន្នន័យដែលជាលទ្ធផលគម្រោង ក៏ដូចជាកង្វល់ បញ្ហាប្រឈម និងសំណូមពរនានាដែលត្រូវរួមគ្នាដោះស្រាយ និងចូលរួមក្នុងកិច្ចប្រជុំ និងការពិគ្រោះយោបល់នានារវាង គ.ជ.ប.ជ និងអង្គការដៃគូ ទៅតាមការអញ្ជើញរបស់ គ.ជ.ប.ជ ឬ គ.ខ.ប.ជ ខេត្តគោលដៅ ។

៦. ចូលរួមតែក្នុងសកម្មភាពដែលមានចែងក្នុងគោលបំណងនៃគម្រោង និងដែលទទួលបានការអនុញ្ញាតពីរាជរដ្ឋាភិបាលកម្ពុជា ដើម្បីសុខុមាលភាពសង្គម ប្រយោជន៍សាធារណៈ ជៀសវាងដាច់ខាតការចូលរួមពាក់ព័ន្ធគ្រប់សកម្មភាពនយោបាយ ។

៧. អង្គការយែរអន្តរជាតិប្រចាំកម្ពុជា មិនអនុញ្ញាតឱ្យភ្នាក់ងាររបស់ខ្លួន ចូលរួមធ្វើរាល់សកម្មភាពទាំងឡាយណាផ្ទុយពីច្បាប់ ដែលអាចប៉ះពាល់ដល់សុវត្ថិភាព ស្ថិរភាព សន្តិសុខ និងសណ្តាប់ធ្នាប់សង្គម ឬសកម្មភាពដទៃទៀតដែលអាចបង្កអន្តរាយដល់ការឯកភាពជាតិ វប្បធម៌ និងប្រពៃណីជាតិរបស់ពលរដ្ឋកម្ពុជា។

៨. ផ្តល់របាយការណ៍ស្តីពីលទ្ធផលនៃកិច្ចសហប្រតិបត្តិការប្រចាំត្រីមាស ឆមាស និងឆ្នាំ ពាក់ព័ន្ធនឹងសកម្មភាព បទពិសោធន៍ ករណីសិក្សាជោគជ័យ បញ្ហាប្រឈម និងទិសដៅបន្តរបស់គម្រោងជូន អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ និងចម្លងជូន គ.ខ.ប.ជ ក្នុងខេត្តគោលដៅ ។

# ប្រការ ៤
# ការដោះស្រាយវិវាទ

រាល់វិវាទដែលអាចកើតឡើងពាក់ព័ន្ធនឹងការបកស្រាយ ឬការអនុវត្តកិច្ចព្រមព្រៀងនេះ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអង្គការឃែរអន្តរជាតិប្រចាំកម្ពុជា ត្រូវដោះស្រាយតាមរយៈការចរចាដោយសន្តិវិធីរវាងភាគីទាំងពីរ។

# ប្រការ ៥
# អវសានប្បញ្ញត្តិ

កិច្ចព្រមព្រៀងនេះ ចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខា និងមានសុពលភាពរហូតដល់គម្រោងត្រូវបានបញ្ចប់តាមកាលកំណត់ (ដូចមានចែងក្នុងឧបសម្ព័ន្ធ) ហើយអាចបន្តសុពលភាពបាន ដោយមានការយល់ព្រមពីភាគីទាំងពីរ។

ភាគីម្ខាងអាចជូនដំណឹងទៅភាគីម្ខាងទៀតជាលាយលក្ខណ៍អក្សរ ក្នុងពេលណាក៏បានប្រសិនបើខ្លួនមានបំណងបញ្ចប់កិច្ចព្រមព្រៀងនេះ។ កិច្ចព្រមព្រៀងនឹងត្រូវបញ្ចប់ក្នុងរយៈពេល ៦០ (ហុកសិប) ថ្ងៃ គិតចាប់ពីកាលបរិច្ឆេទនៃការទទួលបានការជូនដំណឹង។

កិច្ចព្រមព្រៀងនេះ ធ្វើឡើងជាពីរច្បាប់ដើម ជាភាសាខ្មែរ និងភាសាអង់គ្លេស ដែលអត្ថបទទាំងពីរភាសាមានតម្លៃស្មើគ្នា។ ក្នុងករណីមិនមានការឯកភាពគ្នាលើការបកស្រាយអត្ថបទទាំងនេះ អត្ថបទជាភាសាខ្មែរត្រូវយកជាគោល ។

**ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី...៣១....ខែ....ធ្នូ..........ឆ្នាំ២០២០**

**គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ)**
**អនុប្រធានអចិន្ត្រៃយ៍**

លោកជំទាវ **ជូ ប៊ុនអេង**

**អង្គការឃែរអន្តរជាតិប្រចាំកម្ពុជា**

លោក **ម៉ូត សារណា**

# ឧបសម្ព័ន្ធ

## សេចក្តីបរិយាយអំពីគម្រោង

- ឈ្មោះគម្រោង ៖ ចំណាកស្រុកឆ្លងដែនដោយសុវត្ថិភាព
- ឈ្មោះអង្គការ ៖ អង្គការឃែរអន្តរជាតិប្រចាំកម្ពុជា
- ប្រភេទអង្គការ ៖ អង្គការអន្តរជាតិ
- អាសយដ្ឋាន ៖ ប្រអប់សំបុត្រលេខ ៥៣៧ ផ្ទះលេខ ៩១ ផ្លូវលេខ៩៥ សង្កាត់បឹងត្របែក ខណ្ឌ ចំការមន រាជធានីភ្នំពេញ
- ទូរស័ព្ទ ៖ (៨៥៥)២៣ ២១៦ ២៦៧/៨/៩ ទូរសារ៖ (៨៥៥)២៣ ៤២៦ ២៣៣
- អ៊ីម៉ែល ៖ sana.mot@carint.org / khm.info@careint.org
- ទីកន្លែងរបស់គម្រោង៖ ប្រទេសកម្ពុជា (ខេត្តកំពង់ស្ពឺ ខេត្តព្រះសីហនុ) និងប្រទេសថៃ
- ក្រុមគោលដៅរបស់គម្រោង៖ ក្រុមងាយរងគ្រោះ ជាស្ត្រី ក្រុមជនជាតិដើមភាគតិច យុវជន កុមារា កុមារី ដែលប្រឈមនឹងការចំណាកស្រុកដោយគ្មានសុវត្ថិភាព និងការជួញដូរមនុស្ស
- ស្ថាប័នផ្តល់ជំនួយ ៖ ភ្នាក់ងារអង្គការសហប្រជាជាតិលើកកម្ពស់សមភាពយេនឌ័រ និងផ្តល់ភាពអង់អាចដល់ស្ត្រី (UN-WOMEN) នៃកម្មវិធីសុវត្ថិភាព និងយុត្តិធម៌
- ថវិកាគម្រោងសរុប ៖ ២៤៩,៥០០ ដុល្លារសហរដ្ឋអាមេរិក
- គម្រោងចាប់ផ្តើម ៖ ថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០១៩ (បានចុះកិច្ចសហការនៅថ្ងៃ..................)
- គម្រោងបញ្ចប់ ៖ ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២២
- ចំនួនបុគ្គលិកគម្រោង៖ ៣រូប

## សកម្មភាពសំខាន់ៗដែលត្រូវអនុវត្ត ៖

សកម្មភាពគម្រោងរួមមាន៖

- ពង្រឹងក្រុមសហគមន៍ បណ្តាញ ឬក្រុមមិត្តអប់រំមិត្ត ដែលមានស្រាប់ក្នុងខេត្តគោលដៅនៅក្នុងប្រទេសកម្ពុជា និងប្រទេសថៃ។
- បង្កើតក្រុមសហគមន៍ បណ្តាញ ឬក្រុមមិត្តអប់រំមិត្តថ្មី ក្នុងខេត្តគោលដៅនៅក្នុងប្រទេសកម្ពុជា និងប្រទេសថៃ។
- ភ្ជាប់ទំនាក់ទំនងក្រុមសហគមន៍ បណ្តាញ ក្រុមមិត្តអប់រំមិត្តដែលមានស្រាប់ និងបង្កើតថ្មីក្នុងខេត្តគោលដៅនៅក្នុងប្រទេសកម្ពុជា និងប្រទេសថៃ។
- រៀបចំឯកសារបណ្តុះបណ្តាលលើកកម្ពស់ការទប់ស្កាត់អំពើហិង្សាលើស្ត្រី និងការជួញដូរមនុស្ស និងសេវាគាំទ្រជនរងគ្រោះដោយអំពើហិង្សា និងរងគ្រោះដោយការជួញដូរមនុស្ស។
- បណ្តុះបណ្តាលដល់ជនបង្គោលក្នុងសហគមន៍ បណ្តាញឬក្រុមមិត្តអប់រំមិត្ត អំពីការលើកកម្ពស់ការធ្វើចំណាកស្រុកដោយសុវត្ថិភាពនិងកិច្ចការពារប្រឆាំងអំពើជួញដូរមនុស្សឱ្យមានប្រសិទ្ធភាព។
- ក្រុមជនបង្គោលដែលទទួលបានការបណ្តុះបណ្តាល ត្រូវលើកកម្ពស់ការអនុវត្តចំណេះដឹងដល់សមាជិកសហគមន៍នៅក្នុងមូលដ្ឋាន។
- កិច្ចប្រជុំឆ្លុះបញ្ចាំងប្រចាំឆ្នាំជាមួយអ្នកពាក់ព័ន្ធ។